# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃ សុក្រ ០៨កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០២០

## កិច្ចព្រមព្រៀង
## រវាង
## ក្រុមហ៊ុន ធីអេស ខនសិប (ខេមបូឌា)
## និង
## ប្រធានប្រតិភូតបុគ្គលិក

**កម្មវត្ថុ៖** សំណើសុំបន្តការព្យួរកិច្ចសន្យាការងារបុគ្គលិក

ដោយក្រុមហ៊ុនមានវិបត្តិហិរញ្ញវត្ថុយ៉ាងធ្ងន់ធ្ងរក្នុងអំឡុងពេលនៃការវាយលុកពីមេរោគកូវីដ១៩នៅក្នុង ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាក្នុងពិភពលោកទាំងមូល, ក្រុមហ៊ុន បានបាត់បង់អតិថិជនជាច្រើន ជាហេតុនាំអោយក្រុមហ៊ុនសម្រេចចេញសេចក្តីព្រមព្រៀងបន្តស្តីពីការព្យួរការងាររបស់បុគ្គលិកទាំងអស់ ដូចមានចែងដូចខាងក្រោម៖

ប្រាក់ឈ្នួលប្រចាំខែ ត្រូវបានបន្តផ្អាកក្នុងការផ្តល់ជូនរហូតដល់ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០២០ ឬដល់ពេលមានការប្រកាសជូនដំណឹងជាថ្មី។ ប្រាក់ឧបត្ថម្ភចំនួន ៩០ដុល្លាអាមេរិចក្នុងមួយខែ ត្រូវបានកាត់បន្ថយមកនៅត្រឹម ៣០ដុល្លាអាមេរិចក្នុងមួយខែជូនដល់បុគ្គលិកទាំងអស់ ជារៀងរាល់ចុងខែនិមួយៗ។

ក្រុមហ៊ុនសង្ឃឹមយ៉ាងមុតមាំថា បុគ្គលិកទាំងអស់នឹងយល់ពីស្ថានភាពបច្ចុប្បន្ន និងរក្សានៅការផ្តល់ដំណឹងពីការផ្លាស់ប្តូរអាស័យដ្ឋាន ឬលេខទំនាក់ទំនង ដើម្បីងាយស្រួលក្នុងការជូនដំណឹងផ្សេងៗក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះ។

កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០២០ ឬដល់ពេលដែលមានការជូនដំណឹងជាថ្មីពីថ្នាក់ដឹកនាំ។

| ប្រធានផ្នែកធនធានមនុស្ស | ប្រតិភូតបុគ្គលិកនៃក្រុមហ៊ុន ធីអេសខនសិប (ខេមបូឌា) |
|---|---|
| ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ធីអេស ខនសិប (ខេមបូឌា) TS CONCEPT (CAMBODIA) Co., Ltd. KINGDOM OF CAMBODIA | |